# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៩...សសរ

## សេចក្តីសំរេច

### ស្តីពី

### ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ

~~~~~~~~~~~~

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ស ំ រេ ច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ នៅបណ្តាប្រទេសលើពិភពលោក ។
~~~~~~~~~~~~

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះមានសមាសភាពដូចតទៅ:

| | | |
|---|---|---|
| ១-ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២-ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម **គួច គី** | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤-ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៥-ឯកឧត្តម **គោស៊ី សារឿត** | អគ្គនាយក ក្រសួងទេសចរណ៍ | សមាជិក |
| ៦-ឯកឧត្តម **ហាប់ សុត** | អគ្គនាយក ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | សមាជិក |
| ៧-ឯកឧត្តម **គ៉ី សារ៉ុន** | អគ្គនាយក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៨-លោក **សម សម្បត្តិ** | អគ្គនាយករង ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩-លោក **ម៉ុន លាង** | អគ្គនាយករង ក្រសួង ឧស្សាហកម្មរ៉ែ និង ថាមពល | សមាជិក |
| ១០- លោក **ប៉ាក សុខុម** | ប្រធាននាយកដ្ឋានទីផ្សារ និងផ្សព្វផ្សាយក្រសួងទេសចរណ៍ | សមាជិក |
| ១១-លោក **អៀង ស៊ុនលី** | អនុប្រធានទី១ នាយកដ្ឋានថវិកានិយតកម្ម និងហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១២-លោក **ស៊ីន សុថា** | អនុប្រធាននាយកដ្ឋានជំរុញការនាំចេញក្រសួងពាណិជ្ជកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ១៣-លោក **សុខន ឫទ្ធិគុណា** | អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ១៤-លោក **សៅ ស៊ីសុវណ្ណា** | អនុប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៥-លោក **ហេង សោភ័ណ្ឌ** | អនុប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ១៦-លោក **ជា គៀត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ និង ជំរុញវិនិយោគឯកជន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៧-លោក **សុខ ដារិទ្ធិ** | ប្រធានការិយាល័យបច្ចេកទេស និងប្រតិបត្តិ នាយកដ្ឋានជំរុញការនាំចេញ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៨-លោក **អ៊ូ ព្រាំទីរះ** | អនុប្រធានការិយាល័យពត៌មាន និងផ្សព្វផ្សាយ នាយកដ្ឋានជំរុញការនាំចេញ ក្រសួងពាណិជ្ជកម្ម | សមាជិក |

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ:

-ចូលរួមពិព័រណ៍ពិភពលោក នៅទីក្រុងណាហ្គោយ៉ានៃប្រទេសជប៉ុន ពិព័រណ៍ ២០០៥ អាយជី ក៏ដូចជាពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ និង ពិព័រណ៍ពិភពលោកបន្តបន្ទាប់ ដើម្បីបំរើការតាំងពិព័រណ៍ពិភពលោក នៃបណ្តាប្រទេសផ្សេងៗ លើពិភពលោក ។

-ធ្វើទំនាក់ទំនងជាមួយភាគីម្ចាស់ផ្ទះដើម្បីចូលរួមពិព័រណ៍អន្តរជាតិ និង ពិព័រណ៍ពិភពលោក

-ធ្វើទំនាក់ទំនងជាមួយបណ្តាក្រសួង ស្ថាប័ន អង្គការជាតិ-អន្តរជាតិ និង ក្រុមហ៊ុននានា ដែលពាក់ព័ន្ធដើម្បីត្រៀមលក្ខណៈក្នុងការចូលរួមពិព័រណ៍ពិភពលោក ។

-ទទួលខុសត្រូវ និង ចាត់ចែងពីការងាររៀបចំសាងសង់ពន្លាជាតិ និង សំរបសំរួលការទទួលខុសត្រូវចំពោះស្តង់ផ្នែកឯកជន ។

-ជំរុញការតាំងពិព័រណ៍របស់ព្រះរាជាណាចក្រកម្ពុជាយើង អោយបានទទួលជោគជ័យយ៉ាងត្រចះត្រចង់ នៅទីក្រុង ណាហ្គោយ៉ា នៃប្រទេសជប៉ុនខាងមុខនេះ ក៏ដូចជាពិព័រណ៍ពិភពលោកនាឆ្នាំបន្តបន្ទាប់ នៅបណ្តាប្រទេសលើ ពិភពលោក ។

-ចូលរួមសន្និសីទ និង សកម្មភាពទាំងឡាយដែលរៀបចំ និង ប្រព្រឹត្តិទៅរបស់ការិយាល័យរៀបចំពិព័រណ៍អន្តរជាតិ ។

-លើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចក្នុងករណីចាំបាច់ និង ធ្វើរបាយការណ៍បូកសរុបលទ្ធផលជូនទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រសួងពាក់ព័ន្ធ នៅពេលពិព័រណ៍ពិភពលោកមួយលើកៗ ត្រូវបានបញ្ចប់ ។

**ប្រការ ៤ :** នាយកដ្ឋានជំរុញការនាំចេញ នៃក្រសួងពាណិជ្ជកម្ម ជាលេខាធិការដ្ឋាន នៃគណៈកម្មការអន្តរក្រសួងនេះ ដើម្បីរៀបចំ និង ចូលរួមពិព័រណ៍ពិភពលោក និង ពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ។

**ប្រការ ៥ :** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវពិនិត្យ និង ផ្តល់ថវិកា សំរាប់ចំណាយជូនដល់គណៈប្រតិភូដែលត្រូវអញ្ជើញទៅ ចូលរួមការតាំងពិព័រណ៍ពិភពលោក និង ពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ។

**ប្រការ ៦ :** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួនសំរាប់ជំនួយការងារ ។

**ប្រការ ៧ :** គណៈកម្មការអន្តរក្រសួងនេះ ត្រូវស្ថិតនៅជានិរន្តន៍ និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ កុម្ភៈ ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ